អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែងការពិសោធន៍ស៊ុត**

**វិទ្យាសាស្ត្រ**

**ការរស់នៅប្រចាំថ្ងៃ** (ការស្វែងយល់ដោយសង្កេត)

(អំពីរាងកាយផ្ទាល់ខ្លួន)

(លក្ខណៈរូបធាតុ)

**គោលបំណង** ៖

**(វិទ្យាសាស្ត្រ)** ប្រាប់បានពីរបៀបនៃការពិសោធន៍។

ប្រាប់ឈ្មោះផ្នែកផ្សេងៗនៃរាងកាយរបស់មនុស្ស។

ប្រាប់ពីភាពខុសគ្នាវត្ថុធាតុដើមនៃសម្ភារដោយប្រើបញ្ញត្តិដូចជារឹង ទន់។

**រយៈពេល៖** ៣០ នាទី

**ឧបករណ៍** ៖ ត្រូវរៀបចំឧបករណ៍មួយចំនួនដូចជា ស៊ុត២គ្រាប់ ថង់មួយចំនួនសម្ភារមួយចំនួន ដែលអាចប្រើសម្រាប់ខ្ចប់ស៊ុតបាន (ជ្រើសរើសសម្ភាររឹង និងទន់ ដូចជា៖ ថង់ប្លាស្ទិកថ្លា ក្រដាស ក្រណាត់ ឬ អេប៉ុងទន់ ដីខ្មៅពណ៌) មួកការពារសុវត្ថិភាព (ទៅតាមចិត្ត) និងសន្លឹកកិច្ចការ

**ការរៀបចំ** ៖ អនុវត្តដំបូងដើម្បីធ្វើឱ្យប្រាកដថាការពិសោធន៍ធ្វើការជាមួយវត្ថុធាតុដើម ដែលអ្នកបានជ្រើសរើស។ បោះពុម្ពរូបភាពរបស់យ៉េកដែលមានពាក់មួកការពារសុវត្ថិភាព (រឿង«យក្សចម្លែក»)

**សេចក្តីណែនាំ៖**

1. និយាយ៖ ថ្ងៃនេះអ្នកគ្រូនឹងលេង**ល្បែងការពិសោធន៍ស៊ុត** ជាមួយកូនៗទាំងអស់គ្នា។
2. បង្ហាញរូបភាពរបស់យ៉េកពាក់មួកសុវត្ថភាពទៅឱ្យក្មេងៗមើល។
3. សួរក្មេងៗថា៖ តើនៅលើក្បាលរបស់យ៉េកគឺពាក់អ្វី? គឺពាក់មួកសុវត្ថភាព។
   តើហេតុអ្វីបានជាកូនៗគិតថាគាត់ពាក់មួកសុវត្ថភាព? ពីព្រោះ យ៉េកជិះម៉ូតូពាក់មួកសុវត្ថភាពការពារក្បាល។
4. តើកូនៗគិតថានឹងមានអ្វីកើតឡើងប្រសិនបើខួរក្បាលមនុស្សម្នាក់ខូច? ប្រហែលជាមិនអាចនិយាយ ដើរ មើលថែរខ្លួនឯង និងធ្វើរឿងដែលសំខាន់ៗបានឡើយ។
5. សួរសំណួរ៖ តើមានអ្វីនៅក្នុងក្បាលរបស់ពួកយើង? មានខួរក្បាល។
   តើកូនៗគិតថាខួរក្បាលមានតួនាទីធ្វើអ្វីខ្លះ? អាចត្រួតត្រាអ្វីទាំងអស់។

6. បន្ទាប់មកពន្យល់ពួកគេថា៖ ខួរក្បាលអាចគ្រួតត្រាអ្វីទាំងអស់ដែលអ្នកធ្វើដូចជា៖ ចលនារបស់អ្នក អារម្មណ៍របស់អ្នក ការគិតរបស់អ្នក និងមានអ្វីផ្សេងទៀតជាច្រើនដែលទាក់ទងនឹងសារពាង្គកាយរបស់អ្នក។
7. សួរក្មេងៗថា៖ តើមានសារៈសំខាន់អ្វីបានជាយើងពាក់មួកសុវត្ថិភាព? មួកសុវត្ថិភាពអាចការពារក្បាលបាន។ វាអាចការពារការប៉ះទង្គិចពីវត្ថុរឹងមួយចំនួន ដូចជាពេលគ្រោះថ្នាក់ចរាចរណ៍ ដួល។
8. បង្ហាញមួកសុវត្ថិភាព។ ចូរកូនៗប្រើអារម្មណ៍ចំពោះផ្នែកខាងក្រៅ និងខាងក្នុងរបស់មួកសុវត្ថិភាព។ សួរក្មេងៗថា៖ នៅពេលកូនៗប៉ះមួកសុវត្ថិភាព តើវារឹង ឬ ក៏ទន់នៅផ្នែកខាងក្រៅ? បាទ/ចាស រឹង
    - តើនៅផ្នែកខាងក្នុងមួកសុវត្ថិភាពវិញយ៉ាងណាដែរ? បាទ/ចាស ទន់
    - ហេតុអ្វីបានជាវាមានសភាពរឹងនៅខាងក្រៅ ? បាទ/ចាស សម្រាប់ការពារពេលគ្រោះថ្នាក់
    - ហេតុអ្វីនៅខាងក្នុងមួកសុវត្ថភាពទន់? បាទ/ចាស វាជាអេប៉ុងការពារក្បាល។
9. បង្ហាញស៊ុតហើយនិយាយថា៖ស៊ុតប្រៀបដូចជាក្បាលរបស់យើងអញ្ចឹងដែរ។ ខាងក្នុងមានពណ៌លឿង និងពណ៌សប្រៀបដូចជាខួរក្បាលមនុស្សឯខាងក្រៅគឺជាសំបកប្រៀបដូចលលាក្បាលមនុស្សដែរ។
10. បង្ហាញការពិសោធន៍ស៊ុតលើកទី១។ដាក់ស៊ុតមួយនៅក្នុងថង់ប្លាស្ទិចហើយលើកឰ្យប្រហែល កន្លះម៉ែត្រពីលើតុ។
11. សួរកុមារពីអ្វីដែលពួកគេគិតថានឹងកើតឡើងនៅពេលអ្នកទម្លាក់ស៊ុត។ ហេតុអ្វី? ក្មេងអាចឆ្លើយ៖ បែក មិនបែក ។ពីព្រោះ សំបកស៊ុតរឹង សំបកស៊ុតទន់។
12. ទម្លាក់ស៊ុតឱ្យក្មេងៗមើល។
13. ពិភាក្សាម្តងទៀតនិយាយពីលទ្ធផលជាក់ស្តែង។តើកូនៗឃើញស៊ុតមានសភាពយ៉ាងណាដែរ?
14. បង្ហាញការពិសោធន៍ស៊ុតលើកទី២ ។រុំស៊ុតមួយទៀតជាមួយក្រណាត់ រួចដាក់ស៊ុតរុំក្រណាត់នោះក្នុងថង់ប្លាស្ទិចហើយលើកឰ្យប្រហែល កន្លះម៉ែត្រពីលើតុ។
15. សួរកុមារពីអ្វីដែលពួកគេគិតថានឹងកើតឡើងនៅពេលអ្នកទម្លាក់ស៊ុតចុះ។ ហេតុអ្វី? ក្មេងអាចឆ្លើយ៖ បែក មិនបែក ។ពីព្រោះ សំបកស៊ុតរុំក្រណាត់រឹង សំបកស៊ុតទន់។
16. ទម្លាក់ស៊ុតឱ្យក្មេងៗមើល។
17. ពិភាក្សាម្តងទៀតនិយាយពីលទ្ធផលជាក់ស្តែង។ តើកូនៗឃើញស៊ុតមានសភាពយ៉ាងណាដែរ?
18. ប្រសិនបើមានពេលគ្រប់គ្រាន់ឱ្យដីខ្មៅពណ៌ និងផាត់ពណ៌លើសន្លឹកកិច្ចការ